# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្តីពី

# កិច្ចសហប្រតិបត្តិការបច្ចេកទេស

# ឆ្នាំ២០១១

**រាជរដ្ឋាភិបាលកម្ពុជា**

**និង**

**រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

ក្នុងស្មារតីទំនាក់ទំនងជាមិត្តភាពដែលមានកន្លងមករវាងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងព្រះរាជាណាចក្រកម្ពុជា ក្នុងបំណងពង្រឹង និងរឹតចំណងមិត្តភាពតាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីភាពជាដៃគូ កិច្ចព្រមព្រៀងនេះបង្កើតជាមូលដ្ឋានគ្រឹះនៃការថែរក្សាទំនាក់ទំនងនោះ ក្នុងគោលបំណងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា យោងតាមកំណត់ហេតុកិច្ចចរចារវាងរដ្ឋាភិបាលទាំងពីរនៅទីក្រុងបោន (Bonn) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ និងអនុលោមតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ និងថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១០

បានព្រមព្រៀងដូចខាងក្រោមៈ

**មាត្រា១**

(១) អនុលោមតាមកិច្ចព្រមព្រៀងថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពី កិច្ចសហប្រតិបត្តិការបច្ចេកទេស គម្រោងនានាខាងក្រោមនេះត្រូវបានជម្រុញសម្រាប់ការអនុវត្ត :

១. សុខភាពមាតា និងទារក (Mother – Child Health)
២. កម្មវិធីស្តីពីការគាំពារសុខភាពសង្គម ដំណាក់កាលទី ២ (Programme on Social Health Protection II)
៣. កម្មវិធីស្តីពីសិទ្ធិលើដីធ្លី ដំណាក់កាលទី ២ (Programme on Land Rights II)
៤. ការគាំទ្រអាជ្ញាធរសវនកម្មជាតិ ដំណាក់កាលទី ៣ (Support to National Audit Authority III)
៥. កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ដំណាក់កាលទី ៤ (Administrative Reform and Decentralization IV)
៦. អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដំណាក់កាលទី ៤ (Indentification of Poor Housholds – ID Poor IV)
៧. ហិរញ្ញប្បទានសម្រាប់ការសិក្សា និងជំនាញការ (Study and Expert Fund)

ប្រសិនបើការសិក្សាបានរកឃើញថាគម្រោងទាំងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជម្រុញការអនុវត្ត ។

(២) សម្រាប់គម្រោងទាំងឡាយដែលបានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការផ្ទាល់របស់ខ្លួនសរុបចំនួន **១១.១៣០.០០០ អឺរ៉ូ** (ដប់មួយលានមួយរយសាមសិបពាន់អឺរ៉ូ) ក្រោមទម្រង់ជា បុគ្គលិក ធាតុចូល និងវិភាគទានហិរញ្ញវត្ថុសមស្រប ។ GIZ ជាអង្គភាពទទួលបន្ទុកអនុវត្តគម្រោងទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

(៣) រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាថាគម្រោងនីមួយៗដែលមានខ្ទង់ថវិកាផ្ទាល់របស់ខ្លួន ការអនុវត្តនឹងត្រូវដំណើរការយ៉ាងរលូន និងត្រូវធានាឱ្យបានថាស្ថាប័នទទួលបន្ទុកការអនុវត្តនឹងផ្តល់នូវការគាំទ្រចាំបាច់នានាសម្រាប់គម្រោងទាំងឡាយដែលបានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

(៤) គម្រោងទាំងឡាយដែលបានចែងនៅក្នុងកថាខ័ណ្ឌ (១) ១-៧ ខាងលើអាចជំនួសដោយគម្រោងផ្សេងៗទៀតបានដោយមានការឯកភាពគ្នារវាង រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

(៥) ការសន្យាផ្តល់សម្រាប់គម្រោងដែលបានចែងក្នុងកថាខ័ណ្ឌ (១) ១-៧ ខាងលើ និងចំនួនហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសដែលបានចែងក្នុងកថាខ័ណ្ឌ (២) ខាងលើ នឹងត្រូវអស់សុពលភាពក្នុងការអនុវត្តដោយមិនមានការជំនួសអ្វីទាំងអស់ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងឡាយមិនត្រូវបានអនុវត្តដោយផ្អែកតាមមាត្រាទី២ នៃកិច្ចព្រមព្រៀងនេះ ក្នុងរយៈពេលប្រាំបីឆ្នាំ បន្ទាប់ពីឆ្នាំដែលការសន្យាបានធ្វើឡើង ។ ដោយមិនមាន ការរំលោភដល់ខ្លឹមសារដែលបានចែងក្នុងកថាខ័ណ្ឌ (៤) ខាងលើ កាលបរិច្ឆេទផុតកំណត់សម្រាប់ការសន្យា ដែលបានធ្វើឡើងមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ។ ប្រសិនបើ ស្ថិតក្នុងពេលវេលាកំណត់នេះ កិច្ចព្រមព្រៀងអនុវត្តគម្រោង និង កិច្ចព្រមព្រៀងហិរញ្ញប្បទាន ត្រូវបានធ្វើឡើងតែមួយផ្នែកនៃការសន្យា ការលុបចោលត្រូវអនុវត្តចំពោះតែចំនួនដែលនៅសល់ប៉ុណ្ណោះ មិនគ្របដណ្តប់ទៅលើកិច្ចព្រមព្រៀងទាំងមូលឡើយ ។

## មាត្រា២

សេចក្តីលម្អិតនៃគម្រោងដែលបានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងបច្ចុប្បន្ន និងវិភាគទាន ព្រមទាំងកាតព្វ-កិច្ចទាំងឡាយត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដោយឡែកៗពីគ្នា

ដែលត្រូវបានកំណត់ដោយស្ថាប័នទទួលបន្ទុកផ្នែកតាមមាត្រា ១ (២) និង (៣) នៃកិច្ចព្រមព្រៀងនេះ។ កិច្ចព្រម-ព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

(១) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកបង់ពន្ធសម្រាប់ការនាំចូលសម្ភារៈបរិក្ខារ យានយន្ត និងគ្រឿងបន្លាស់ សម្រាប់ការអនុវត្តគម្រោងផ្នែកលើមាត្រា១ (១) នៃកិច្ចព្រមព្រៀងនេះ និងការចំណាយក្នុងនាមរបស់រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ទៅលើ អាជ្ញាប័ណ្ណ ពន្ធគយ ពន្ធនាំចូល ពន្ធនាំចេញ និងការបង់ថ្លៃសម្រាប់សេវាសាធារណៈផ្សេងៗ រួមទាំងថ្លៃឈ្នួលឃ្លាំង និងត្រូវធានាថាការបំពេញបែបបទគយត្រូវដំណើរការដោយគ្មានការយឺតយ៉ាវឡើយ ។

(២) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវធានាបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋនូវថ្លៃសេវាសាធារណៈទាំងអស់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាជំនួសដោយ GIZ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

យោងតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ ហិរញ្ញប្បទានសហប្រតិ-បត្តិការនៃគម្រោង អភិវឌ្ឍន៍ជនបទតំបន់សហគមន៍ខេត្តកំពត និងកំពង់ធំ ដំណាក់កាលទី២ (Community Based Rural Development Project Kampot and Kampong Thom) ចំនួន **៨២០.០០០ អឺរ៉ូ** នឹងផ្ទេរមកប្រើប្រាស់ក្នុងគម្រោង "អភិវឌ្ឍន៍សេដ្ឋកិច្ចតាមតំបន់ ដំណាក់កាលទី ២ (Regional Economic Development – RED II)" ដែលមានចែងក្នុងកិច្ចព្រមព្រៀងបច្ចេកទេសសម្រាប់ឆ្នាំ ២០០៩ និងចុះហត្ថលេខានៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១០ ប្រសិនបើការសិក្សារកឃើញថាគម្រោងមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជម្រុញការអនុវត្ត ។

## មាត្រា ៥

ដោយផ្អែកតាមមាត្រា ១ (១) ខាងលើ រាល់លក្ខខ័ណ្ឌដែលចែងនៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងបច្ចុប្បន្ននេះ ។

## មាត្រា ៦

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញថ្ងៃទី 9. August 2012 មាន ២ ច្បាប់ដើមចម្លងជាបីភាសាគឺ ភាសាខ្មែរ អាល្លឺម៉ង់ និង អង់គ្លេស អត្ថបទទាំង ៣ ភាសានេះមានតំលៃដូចគ្នា ។ ក្នុងករណីការបកប្រែមិនស្របមតិគ្នារវាងអត្ថបទ ភាសាខ្មែរ និងអាល្លឺម៉ង់ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

| | |
|---|---|
| **តំណាង** | **តំណាងរដ្ឋាភិបាល** |
| **រាជរដ្ឋាភិបាលកម្ពុជា** | **សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់** |
| Keat Chhon | |